01475726

**Declassified to Public**
**27 June 2019**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 05 / 2017
ម៉ោង (Time/Heure) : 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/35/14

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៧

**ជូនចំពោះ÷** Michael BOHLANDER សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ.)

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ
លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីទាំងអស់នៃសំណុំរឿង ០០២

**កម្មវត្ថុ÷** សិទ្ធិក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២

១. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាបានដាក់សំណើមួយដោយស្នើសុំថា ដោយនត្ថិភាពនូវមូលហេតុសមហេតុផល ក្នុងការរក្សាទុកនូវការកោសលុបនៃប្រតិចារឹកក្នុងសំណុំរឿង ០០២/០២ ឬ ការរក្សាទុកការប្រើប្រាស់រហស្សនាមសម្រាប់សាក្សីក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះគួរកំណត់ប្រតិចារឹកទាំងអស់នៃសំណុំរឿង ០០២/០២ ទៅជាសាធារណៈយ៉ាងពេញលេញ (សំណើរបស់ ក.ស.ព.) (ឯកសារ E319/35/7 កថាខណ្ឌ ៤)។ នៅថ្ងៃទី០៣ ខែ មីនា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជូនសំណើរបស់ ក.ស.ព. ទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ.) ដោយស្នើសុំមតិយោបល់របស់លោក

ថាតើសុចរិតភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ នៅតែតម្រូវឱ្យមានវិធានការដែលបានអនុវត្តចំពោះប្រតិចារឹក និងសាក្សីនៅក្នុងសំណុំរឿង ០០២/០២ ដដែល ឬក៏នៅពេលនេះអាចលុបចោលវិធានការទាំងនេះបានហើយ (ឯកសារ E319/35/8)។ បន្ទាប់ពីមានការស្នើសុំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាបានរៀបរាប់ឈ្មោះសាក្សី និងសក្ខីកម្មនានា ដែលខ្លួនស្នើសុំឱ្យមានការវាយតម្លៃឡើងវិញ (ឯកសារ E319/35/10)។ ស.ច.ស.អ. បានឆ្លើយតបនៅថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០១៧ ដោយបញ្ជាក់ថា ដោយសារតែមានភាពចាំបាច់តម្រូវឱ្យធនធានបុគ្គលិកតិចតួចរបស់ខ្លួនផ្តោតលើភារកិច្ចចម្បងនោះ លោកមិនមានលទ្ធភាពផ្តល់អាទិភាពទៅលើសំណើរបស់ ក.ស.ព. នៅក្នុងអំឡុងពេលវេលាដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលបានទេ (ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧) និងបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យភាគីគោរពតាមវិធានការនានាដែលកំពុងអនុវត្តជាធរមាន (ឯកសារ E319/35/12.1)។ នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ ក.ស.ព. ដោយកត់សម្គាល់ថា "អង្គជំនុំជម្រះពុំមានលទ្ធភាពលុបចោលលក្ខខណ្ឌនៃការកោសលុបប្រតិចារឹក ឬអនុញ្ញាតឱ្យយោងលើឈ្មោះសាក្សីដែលស្ថិតក្រោមលក្ខខណ្ឌការពារតាមអំណាចដីកាបង្គាប់របស់ ស.ច.ស.អ. បានទេ រហូតទាល់តែ ស.ច.ស.អ. បញ្ជាក់ថា ការផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈ លែងប៉ះពាល់ដល់ការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ទៀតហើយ" (ឯកសារ E319/35/12)។

២. ដូចបានកត់សម្គាល់ពីមុនរួចហើយ (ឯកសារ E319/35/5 កថាខណ្ឌ ៥) ការិយាល័យសហ-ចៅក្រមស៊ើបអង្កេត គឺជាការិយាល័យតែមួយគត់ដែលអាចវាយតម្លៃថាតើ កត្តានានាដែលនាំឱ្យមានការដាក់លក្ខខណ្ឌទាំងនោះមានការប្រែប្រួលហើយ ឬ នៅ និងជាពិសេស ថាតើការដាក់បង្ហាញព័ត៌មានដែលស្ថិតក្រោមការការពារនេះ អាចនាំឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងដំណើរការដែរ ឬ យ៉ាងណា។ ទោះបីយ៉ាងណាក្តី ដោយពិចារណាថា ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលនឹងឈានមកដល់ក្នុងពេលឆាប់ៗខាងមុខនេះ គឺត្រូវធ្វើជាសាធារណៈនោះ អង្គជំនុំជម្រះមានការព្រួយបារម្ភថា នត្ថិភាពនៃព័ត៌មានបច្ចុប្បន្នភាពណាមួយពី ស.ច.ស.អ. នឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ ជាពិសេស ប្រសិនបើកាលៈទេសៈបានប្រែប្រួល

ហើយមិនមានយុត្តិកម្មណាមួយក្នុងការរក្សាការសម្ងាត់នៃព័ត៌មានទាំងនេះបានតទៅទៀតទេនោះ។ អាស្រ័យហេតុនេះ ទោះបីជាអង្គជំនុំជម្រះយល់ថា ស.ច.ស.អ. មានបន្ទុកការងារច្រើនក្នុងពេលតែមួយក៏ដោយ ក៏អង្គជំនុំជម្រះស្នើសុំឱ្យ ស.ច.ស.អ. បញ្ជាក់ឱ្យបានឆាប់រហ័សថាតើវិធានការនានាដែលអនុវត្តចំពោះប្រតិចារឹក និងសាក្សីនៅក្នុងសំណុំរឿង ០០២/០២ ដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃសំណើរបស់ ក.ស.ព. (ឯកសារ E319/35/10.1, E319/35/10.2, E319/35/10.3 និង E319/35/10.4) នៅពេលនេះ អាចលុបចោលបានដែរឬទេ។ សវនាការលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវធ្វើចាប់ពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។ យើងខ្ញុំសូមអគុណចំពោះការផ្តល់ចម្លើយតបរបស់លោកឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ដោយសុំមិនឱ្យហួសពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៧។